# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦

**កម្មវិធីផ្លាស់ប្តូរយុវជន** JENESYS 2016

**ប្រធានបទៈ សេដ្ឋកិច្ច** (**ក្រុមទី១**)

តាមរយៈការអញ្ជើញរបស់ក្រសួងការបរទេសជប៉ុន ក្រោមកម្មវិធី JENESYS 2016 ក្រុមយុវជនកម្ពុជាចំនួន២២រូបដែលមានចំណាប់អារម្មណ៍ក្នុងវិស័យសេដ្ឋកិច្ច នឹងធ្វើទស្សកិច្ច ទៅកាន់ប្រទេសជប៉ុន ពីថ្ងៃទី២៨ ខែសីហា ដល់ថ្ងៃទី៦ ខែកញ្ញាជាមួយយុវជនមកពីបណ្តាប្រទេសអាស៊ាន ប្រទេសទីម័រខាងកើត និងប្រទេសឥណ្ឌា ។

កម្មវិធី JENESYS 2016 មានគោលបំណងជម្រុញការយល់ដឹងនិងមានទំនុកចិត្តគ្នាទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុននិងបណ្តាប្រទេសដែលចូលរួម ដើម្បីកសាងមូលដ្ឋានគ្រឹះនៃមិត្តភាពនិងសហប្រតិបត្តិការសម្រាប់អនាគត។

ក្រុមយុវជនដែលបានអញ្ជើញនៅថ្ងៃទី២៨ ខែសីហា នឹងធ្វើទស្សនកិច្ចទៅកាន់ខេត្តអូសាកា ក្យូតូ ស៊ីហ្គា និងខេត្តមីយ៉ាគី ដើម្បីចូលរួមកម្មវិធីផ្លាស់ប្តូរជាមួយនិងបណ្តាស្ថាប័ន និងក្រុមហ៊ុននានា ក្រោមប្រធានបទរង "**ដៃគូសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ**" ។ ពួកគេក៏នឹងមានឱកាសជាច្រើនដើម្បីធ្វើទស្សកិច្ច ទៅកាន់អគារប្រវត្តិសាស្ត្រ និងសារៈមន្ទីរវិទ្យាសាស្ត្រ ក៏ដូចជាទទួលបាននូវបទពិសោធវប្បធម៌ជប៉ុន និងការស្នាក់នៅផ្ទះជាមួយជនជាតិជប៉ុន។ ចំពោះកម្មវិធីលំអិតនៃដំណើរទស្សកិច្ចនេះមាននៅក្នុងឯកសារភ្ជាប់។

យើងសង្ឃឹមថានិស្សិតដែលចូលរួមក្នុងកម្មវិធីនេះអាចយល់ដឹងកាន់តែស៊ីជម្រៅអំពីទំនាក់ទនងសេដ្ឋកិច្ចរវាងប្រទេសជប៉ុន និងបណ្តាប្រទេសផ្សេងៗទៀត ព្រមទាំងចែករំលែកបទពិសោធដ៏ទូលំទូលាយរបស់ពួកគេទៅដល់ប្រជាជនកម្ពុជាបន្ទាប់ពីពួកគេវិលត្រលប់មកវិញ។

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ ០២៣ ២១៧ ១៦១ អ៊ីម៉ែលៈ info.jpn@pp.mofa.go.jp*
*គេហទំព័រផ្លូវការៈ www.kh.emb-japan.go.jp*